**កាកបាទក្រហមកម្ពុជា**

# លិខិតថ្លែងអំណរគុណ

**គោរពជូន**

**ឯកឧត្តម យី ទាសនា**

**ទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

**អគ្គលេខាធិការគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា**

**និងជា នាយកប្រតិបត្តិមជ្ឈមណ្ឌលជាតិនៃជនពិការ**

**ឯកឧត្តម ជាទីរាប់អាន**

ខ្ញុំសូមថ្លែងអំណរគុណដោយក្តីសោមនស្សរីករាយយ៉ាងក្រៃលែងចំពោះ **ឯកឧត្តម** និង សហការី សហការិនី គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងមជ្ឈមណ្ឌលជាតិនៃជនពិការទាំងអស់ ដែលបានជូននូវសព្ទសាធុការពរដល់ខ្ញុំ ក្នុងឱកាសដែលខ្ញុំ ទទួលបានគោរមងារជា **ឥស្សរជនឆ្នើមថ្នាក់ជាតិ នៃផែនការសកម្មភាពរួម របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីសុខភាពស្ត្រី និង កុមារ** ព្រមទាំងបានលើកសរសើរ និងវាយតំលៃខ្ពស់ចំពោះ ស្នាដៃ និង សកម្មភាពការងារ របស់ខ្ញុំ លើវិស័យមនុស្សធម៌ សង្គម និងសុខភាព។

ចំពោះពរជ័យសិរីមង្គលរបស់ **ឯកឧត្តម** និងសហការី សហការិនី គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងមជ្ឈមណ្ឌលជាតិនៃជនពិការទាំងអស់ បានលើកទឹកចិត្តយ៉ាងធំធេងដល់រូបខ្ញុំ ក្នុងការបន្តដឹកនាំការងារ កាកបាទក្រហមកម្ពុជា ក៏ដូចជាការងារលើកកម្ពស់សុខុមាលភាពរបស់ស្ត្រី និង កុមារ នៅព្រះរាជាណាចក្រកម្ពុជា ឱ្យបានកាន់តែប្រសើរជាងមុន ដើម្បី ឈានទៅសម្រេចគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍ទី៥ នាឆ្នាំ ២០១៥ ខាងមុខនេះ។

តបទៅនឹងពរជ័យដ៏ថ្លៃថ្លានេះ ខ្ញុំ និង ក្រុមគ្រួសារ សូមប្រសិទ្ធពរជូនចំពោះ **ឯកឧត្តម** និង **លោកជំទាវ** ព្រមទាំងសហការី សហការិនី គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងមជ្ឈមណ្ឌលជាតិនៃជនពិការទាំងអស់ សូមបានប្រកបដោយព្រះពុទ្ធពរ ទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **ឯកឧត្តម** ទទួលនូវក្តីរាប់អានអំពីខ្ញុំ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១១

**ប្រធាន**

**ប៊ុន រ៉ានី ហ៊ុនសែន**

១៦A ផ្លូវលេខ ៦៥២ កែង ២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
16A, Street 652@271, O Bek Kaam, Sangkat Toek Laak 3, Khan Tuol Kork, Phnom Penh, Kingdom of Cambodia
Tel: (855-23) 881 511, Fax:(855-23) 881 522, P.O. Box: 69, Web: www.redcross.org.kh, E-mail: info@redcross.org.kh, crc_adm@online.com.kh